**ប្រកាសអោយប្រើ**

ច្បាប់ ស្តីពីសញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ សីហា ឆ្នាំ ១៩៩៦ នាសម័យប្រជុំ វិសាមញ្ញ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

# ច្បាប់

## ស្តីពី

# សញ្ជាតិ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ ._**

ច្បាប់នេះមានគោលដៅកំណត់សញ្ជាតិខ្មែរ ចំពោះជនដែលបំពេញល័ក្ខខ័ណ្ឌ នៃច្បាប់នេះ ដែលរស់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ឬ នៅបរទេស ។

**មាត្រា ២ ._**

ជនណាមានសញ្ជាតិខ្មែរ ជាប្រជាពលរដ្ឋខ្មែរ ។ ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

**មាត្រា ៣ ._**

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេស ÷

១_ត្រូវបានរដ្ឋគាំពារតាមគ្រប់មធ្យោបាយការទូត

២_មិនអាចបាត់បង់សញ្ជាតិដោយឯកឯង ។

## ជំពូកទី ២

## សញ្ជាតិខ្មែរពីកំណើត

**មាត្រា ៤ ._**

១_ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ÷

_កូនមានខាន់ស្លាដែលកើតមកពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ឬ

_កូនឥតខាន់ស្លាដែលកើតមកពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់ឬ

_កូនដែលឪពុក ម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ ។

២_ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ÷

ក_កូនដែលកើតពីឪពុកនិងម្តាយបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ_កូនដែលកើតពីឪពុក ម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

## ជំពូកទី ៣

## សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

**មាត្រា ៥ .-**

ស្ត្រី ឬ បុរសបរទេសដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍អាចទាមទារ សញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ។

បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ៦ .-**

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

## ជំពូកទី ៤

## សញ្ជាតូបនីយកម្ម

**មាត្រា ៧ .-**

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយពាក្យសុំនោះអាចត្រូវបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិ ។

**មាត្រា ៨ ._**

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញល័ក្ខខ័ណ្ឌដូចតទៅ ÷

១_មានលិខិតបញ្ជាក់ថា មានគំនិតមារយាទនិងសីលធម៌ល្អ ដែលចេញឱ្យដោយមេឃុំ ឬ ចៅសង្កាត់ នៃទីលំនៅរបស់ខ្លួន

២_មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោស ពីបទព្រហ្មទ័ណ្ឌ ណាមួយ

៣_មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួនប្រាំពីរឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលប័ណ្ណស្នាក់នៅដែលចេញអោយ ក្នុងក្របខ័ណ្ឌ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

៤_ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំសញ្ជាតូបនីយកម្ម

៥_ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុមព្រមទាំងទទួល បាននូវទំនៀម ទំលាប់និងប្រពៃណីល្អរបស់ខ្មែរ

៦_ មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬ នាំឱ្យមានបន្ទុកដល់ជាតិ ។

**មាត្រា ៩ ._**

ចំពោះជនបរទេសណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ប្រាំពីរឆ្នាំ ដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវបន្ថយមកនៅបីឆ្នាំវិញ ។

**មាត្រា ១០ ._**

ចំពោះជនបរទេសណា ដែលបានទទួលលិខិតអនុញ្ញាតឱ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយដែលបានអនុញ្ញាតគំរោងដាក់ស្តែងចំណាយទុនចំនួន ចាប់ពីមួយពាន់ពីររយហាសិបលានរៀល (១.២៥០.០០០.០០០រៀល) ឡើងទៅរយៈពេលស្នាក់នៅ ដូចមានចែងក្នុងចំណុចទី៣ មាត្រា ៨ នៃច្បាប់នេះត្រូវបានលើកលែង ។

**មាត្រា ១១ .–**

ចំពោះជនបរទេសណា ដែលពុំមានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តែបាន ទទួលការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ហើយដែលបានចំណាយទុនវិនិយោគ ចាប់ពីចំនួនមួយពាន់ពីររយហា សិបលានរៀល (១.២៥០.០០០.០០០រៀល) ឡើង ទៅរយៈពេលស្នាក់នៅដែលមានចែងក្នុងចំណុច ទី ៣ មាត្រា ៨ នៃច្បាប់នេះត្រូវ បានលើកលែង ។

**មាត្រា ១២ .–**

ជនបរទេសណាដែលបានធ្វើអំណោយជាប្រាក់ដល់ថវិកាជាតិចាប់ពីមួយពាន់លាន រៀល (១.០០០.០០០.០០០រៀល) ឡើងទៅ សំរាប់ជាផលប្រយោជន៍ដល់ការស្តារ និងកសាងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះ អាចធ្វើពាក្យសុំចូល សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបាន បំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុង ចំណុចទី ១, ទី ២, ទី ៥, និងទី ៦ មាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ១៣ .–**

ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬ ថ្វីដៃ ពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា អាចធ្វើពាក្យសុំចូល សញ្ជាតិខ្មែរបានដោយពុំចាំបាច់ បំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី ៣ មាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ១៤ .–**

ជនបរទេសដែលមានសហព័ទ្ធ ឬ កូនដែលមានអាយុតិចជាង ១៨ ឆ្នាំ ដែលមាន បំណង សុំសញ្ជាតិខ្មែរ អាចសុំសញ្ញាប័ត្រូបនីយកម្មជាចង្កោមគ្រួសារ ។

**មាត្រា ១៥ .–**

ជនបរទេសអាចសុំដូរផ្លាស់ឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ ឈ្មោះនោះ ក្នុងពាក្យសុំសញ្ញាប័ត្រូបនីយកម្មរបស់ខ្លួន ។

**មាត្រា ១៦ .–**

សញ្ញាប័ត្រូបនីយកម្មដែលផ្តល់ចំពោះជនណាម្នាក់ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។ បែបបទនិងនីតិវិធីនៃការសុំសញ្ញាប័ត្រូបនីយកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧ ._**

ជនដែលបានអនុញ្ញាតឱ្យចូលជាសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះមានចែងនៅក្នុងអនុក្រឹត្យ ។

## ជំពូកទី ៥

## ការបាត់សញ្ជាតិខ្មែរ

**មាត្រា ១៨ ._**

ជនណាដែលបាត់សញ្ជាតិខ្មែរ ហើយមានអាយុ ១៨ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ ។

នីតិវិធី និងលក្ខខ័ណ្ឌនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ១៩ ._**

មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួល និង កាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២០ ._**

ជនបរទេសណា ដែលកាន់កាប់និងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

**មាត្រា ២១ ._**

ជនណាដែលក្លែង ធ្វើការកោស លុប សរសេរត្រួត ឬ ឱ្យគេខ្ចី ឬ មួយសរសេរឈ្មោះក្លែងក្លាយនៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន នៃ

ព្រះរាជាណាចក្រកម្ពុជា ឬ មួយប្រើប្រាស់ ឯកសារទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។

**មាត្រា ២២ .–**

មន្ត្រី ភ្នាក់ងាររាជការ ឬ ជនណាដែលសមគំនិត ជួយលាក់បាំង ឬ ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនឱ្យជនណាម្នាក់ដែលគ្មាន សញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចគ្នានឹងជនដែល កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា ២០ និងមាត្រា ២១នៃច្បាប់នេះ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៣ .–**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ — ព្រះហស្តលេខានិងត្រា — **នរោត្តម រណប្ញទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — ហត្ថលេខា និងត្រា — **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ហត្ថលេខា និង ត្រា

**ស ខេង** **យូ ហុកគ្រី**

* * *